# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៧ សរណន

## សារាចរណែនាំ
## ស្តីពី
## ការតែងតាំងមន្ត្រីខុទ្ទកាល័យ ទីប្រឹក្សា និងជំនួយការថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, អនុក្រឹត្យលេខ ២០ អនក្រ បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន, អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ជាប្រធានស្ថាប័ន និងបណ្តាលិខិតបទដ្ឋានផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់កន្លងមក និងដើម្បីគ្រប់គ្រងមន្ត្រីរាជការគ្រប់ប្រភេទឲ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសមន្ត្រីដែលបំពេញមុខងារនៅក្នុងខុទ្ទកាល័យរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ នៅតាមក្រសួង និងស្ថាប័ននានា ។

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី ៦ នៃរដ្ឋសភា ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/...៩១៥... ចុះថ្ងៃទី...៦... ខែកញ្ញា ឆ្នាំ២០១៨ សូមធ្វើការណែនាំដូចតទៅ:

១-រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នត្រូវរៀបចំចេញប្រកាសបញ្ចប់តំណែងមន្ត្រីខុទ្ទកាល័យ ទីប្រឹក្សា និងជំនួយការ ដែលបំពេញការងារក្នុងសាមីខុទ្ទកាល័យ អមសាមីក្រសួង ស្ថាប័ន និងក្នុងអង្គភាពចំណុះសាមីក្រសួង ស្ថាប័នទាំងអស់ ដែលទទួលបានការតែងតាំងមុនថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ។

២-ក្រោយពីបានបញ្ចប់តំណែងរបស់ជនទាំងអស់ដូចមានចែងក្នុងចំណុចទី ១ ខាងលើ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន អាចរៀបចំតែងតាំងសាជាថ្មី នូវមន្ត្រីខុទ្ទកាល័យ ទីប្រឹក្សា និងជំនួយការឲ្យបំពេញការងារក្នុងសាមីខុទ្ទកាល័យ អមសាមីក្រសួង ស្ថាប័នឡើងវិញស្របតាម អនុក្រឹត្យ លេខ ២០ អនក្រ បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន និងអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន ។

ទទួលបានសារាចរណែនាំនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**